ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ប្រញាប់ណាស់

ក្រសួងការបរទេស

និងសហប្រតិបត្តិការអន្តរជាតិ

លេខ ២៦៤០ កបទ.សអ/អប១

ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជាសូមសំដែងគារវកិច្ចចំពោះស្ថានទូតនៃសាធារណរដ្ឋសង្គមនិយមវៀតណាមប្រចាំនៅរាជធានីភ្នំពេញ និងមានកិត្តិយស សូមស្នើស្ថានទូតបញ្ជូនសារជូនដល់អាជ្ញាធរពាក់ព័ន្ធរបស់វៀតណាមដូចខាងក្រោម ៖

1. ក្នុងស្មារតីមិត្តភាពនិងការយោគយល់គ្នាទៅវិញទៅមក ទាក់ទងនឹងការការពារការរីករាលដាលនៃវីរុស COVID-១៩ កម្ពុជាសូមស្នើឱ្យអាជ្ញាធរវៀតណាមជូនដំណឹងដល់ពលរដ្ឋវៀតណាមកុំឲ្យធ្វើដំណើរមកប្រទេសកម្ពុជាតាមគ្រប់ផ្លូវគោក ផ្លូវទឹក និងផ្លូវអាកាស ក្នុងអំឡុងពេលសុពលភាពនៃការរឹតត្បិតការធ្វើដំណើររបស់ប្រទេសវៀតណាម ដែលបានចូលជាធរមានចាប់ពីម៉ោងសូន្យព្រឹកថ្ងៃទី ១៨ ខែមីនាឆ្នាំ ២០២០ ។
2. សំណើខាងលើត្រូវបានធ្វើឡើងក្នុងបំណងចៀសវាងមានការលំបាកកើតឡើង នៅច្រកព្រំដែនរួមរវាងប្រទេសទាំងពីរ ដោយយោងលើការកើនឡើងយ៉ាងគំហុកនូវការរកឃើញករណីឆ្លងវីរុស COVID-១៩ ខណៈពេលដែលប្រទេសវៀតណាមបានដាក់កម្រិតលើការធ្វើដំណើរ ដែលតម្រូវឱ្យមានការដាក់នៅដោយឡែកពីគេរយៈពេល១៤ថ្ងៃ ចំពោះអ្នកដំណើរមកពីប្រទេសសមាជិកអាស៊ាន រួមទាំងជនជាតិវៀតណាមដែលវិលត្រឡប់ចូលស្រុកវិញផងដែរ។
3. ការធ្វើដំណើរចូលប្រទេសកម្ពុជាដោយពលរដ្ឋវៀតណាម និង ការធ្វើដំណើរចូលប្រទេសវៀតណាមដោយពលរដ្ឋកម្ពុជា តាមផ្លូវគោក ផ្លូវទឹក និងផ្លូវអាកាសទាំងអស់នឹងត្រូវផ្អាកជាបណ្តោះអាសន្ន ចាប់ពីម៉ោង ២៣:៥៩ យប់ថ្ងៃទី ២០ ខែមីនា ឆ្នាំ២០២០។ វិធានការនេះមានគោលបំណងបញ្ចៀសនូវការលំបាកចំពោះពលរដ្ឋវៀតណាម ក៏ដូចជាពលរដ្ឋកម្ពុជា ដែលតម្រូវឲ្យបង្ខាំងខ្លួននៅដាច់ពីគេ ក្រោយពីបានធ្វើដំណើរពីប្រទេសកម្ពុជា ចូលទៅវៀតណាម។
4. វិធានការខាងលើនេះ មិនត្រូវបានអនុវត្តចំពោះពលរដ្ឋវៀតណាម និង ពលរដ្ឋកម្ពុជា ដែលកាន់លិខិតឆ្លងដែនការទូត និងផ្លូវការទេ។
5. ភាគីកម្ពុជាស្នើឱ្យអាជ្ញាធរមូលដ្ឋាននៃប្រទេសទាំងពីរធ្វើការរួមគ្នាដើម្បីសម្របសម្រួល និងធានាថា ការដឹកជញ្ជូនទំនិញឆ្លងកាត់ព្រំដែនរួម អាចអនុវត្តដោយគ្មានការរាំងស្ទះ។
6. ភាគីកម្ពុជាស្នើសុំឱ្យអាជ្ញាធរមូលដ្ឋាននៃប្រទេសវៀតណាមជួយសម្រួលការធ្វើមាតុភូមិនិវត្តន៍ មកកម្ពុជាវិញនូវពលរដ្ឋកម្ពុជាទាំងអស់ ដែលកំពុងត្រូវបានដាក់ឲ្យនៅដាច់ពីគេ ក្នុងប្រទេសវៀតណាម ប្រសិនបើមាន។

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា សូមឆ្លៀតឱកាសនេះបញ្ជាក់ជាថ្មីពីការវាយតម្លៃខ្ពស់បំផុតចំពោះស្ថានទូតនៃសាធារណរដ្ឋសង្គមនិយមវៀតណាមប្រចាំនៅទីក្រុងភ្នំពេញ។

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែមីនា ឆ្នាំ ២០២០

អាសយដ្ឋានៈ លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855) 23 216 122
ទូរសារ: (855) 23 216 141, 023 213 341
អ៊ីមែល: mfaic@mfaic.gov.kh